ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំព្រហ្មទណ្ឌ
លេខ:៣២៩/០៩-០៤-២០១២
សាលដីកា
លេខ:១៩ ក្រ.ឧ/០៥-៣-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៥ ខែមិនា ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ៣២៩ចុះថ្ងៃទី០៩-៤-២០១២ រវាងៈ

១-ជនជាប់ចោទឈ្មោះ [redacted] ភារុណ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ២ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍)

ឃាត់ខ្លួនថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១០៤គព្រ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ។

-មេធាវីការពារក្តីលោក [redacted] ម៉ាច ។

២-ឈ្មោះ [redacted] តារាវុទ្ធ ហៅវ៉ាន់ ចំរើន ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ ។

៣-ឈ្មោះ [redacted] ម៉េងហុង ហៅតាន់ហុង ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ។

ត្រូវចោទពីបទៈ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តិនៅចំណុចស្តាតអូឡាំពិក សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ ។

១៧៨





Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកចម្រៀងប្រចាំបាប៉ាស៊ីហ្វិកឃើស ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ខណ្ឌ [redacted] ។

## ឯរឿងហេតុមានដូចតទៅៈ

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង០០និង២០នាទីរំលងអាធ្រាត្រ នៅចំណុចតូបលក់ផ្លែឈើស្ថិតនៅក្បែរស្ពាតអូឡាំពិក សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] ភារុណ ហៅពែក និងឈ្មោះ [redacted] តារាវន្ត ហៅវ៉ាន់ ចំរើន និងឈ្មោះ [redacted] ម៉េងហុង បាននាំគ្នាជិះរថយន្តមួយគ្រឿងម៉ាកកាមរី ស៊េរីឆ្នាំ៩០ឬ៩១ ពណ៌ស បានធ្វើសកម្មភាពភ្ជង់ជនរងគ្រោះប្លន់យករថយន្តម៉ាកឡិចស៊ីសRX300 ពីជនរងគ្រោះឈ្មោះ [redacted] លីនដា ភេទស្រី អាយុ២១ឆ្នាំ ដែលកំពុងជិះជាមួយម្ដាយ ។ បន្ទាប់ពីធ្វើសកម្មភាពប្លន់បានសម្រេចហើយ ជនជាប់ក៏បានបើករថយន្តគេចខ្លួនបាត់អស់តែម្ដង ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១១០ កប៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសេចក្ដីសម្រេចដូចតទៅៈ

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ភារុណ ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] តារាវន្ត ហៅ វ៉ាន់ ចំរើន ភេទប្រុស អាយុ៣២ឆ្នាំ ពីមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមមាត្រា៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌវិញ ។

២-ផ្ដន្ទាទោសៈ

ក-ឈ្មោះ [redacted] ភារុណ ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ [redacted] តារាវន្ត ហៅវ៉ាន់ ចំរើន ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួន០៧ឆ្នាំ (ប្រាំពីរឆ្នាំ) និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន១.០០០.០០០រៀល (មួយលានរៀល) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប.ទប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅស្ដាតអូឡាំពិក សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ តាមមាត្រា៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៣-ទុកសិទ្ធិឲ្យជនរងគ្រោះប្ដឹងទាមទារសំណងតាមច្បាប់ ។

៤-វត្ថុតាងមានៈ អាវុធខ្លីមួយដើមម៉ាក K-59 លេខ៣៩៦៩ រួមនិងបង់ចំនួន០១ គ្រាប់ចំនួន០៦គ្រាប់ ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ២៨ អយគ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៥-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១៨៩ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ទៅចៅក្រមស៊ើបសួរចាត់ការលើឈ្មោះ តាន់ ម៉េងហុង តាមនីតិវិធី ។

-សាលក្រមជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភារុណ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] តារាវន្ត ហៅវ៉ាន់ ចំរើននិងជនរងគ្រោះ។ បើកផ្លូវប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

១៧៩

បានឃើញពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-១២-២០១១ របស់ឈ្មោះ [redacted] ភារុណ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១០ កប៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ភារុណ បានឆ្លើយបញ្ជាក់ថា ខ្លួនធ្វើការនៅខេត្តសៀមរាប ជាអ្នកបើកឡានឲ្យគេហើយខ្លួនជាប់ឃុំ៨ឆ្នាំ ២ខែ ១៦ថ្ងៃ គឺពី ថ្ងៃទី១៨-០១-២០១០ ។ សមត្ថកិច្ចចាប់ខ្លួនកំពុងជិះឡានជាមួយមិត្តភក្តិឈ្មោះ ទិត្យ ហើយពេលឆែកឆេរបានកាំភ្លើងមួយដើមជារបស់ឈ្មោះទិត្យ តែវាគេចខ្លួនបាត់នៅពេលនោះ ។ រថយន្តបង្កហេតុជារបស់ខ្លួនមែន តែឈ្មោះ [redacted] តារាវិន្ត ត្រូវជាមិត្តភក្តិខ្លួនខ្ចីទៅជិះ ហើយនៅពេលតទល់ចម្លើយវាថាខ្ចីឡានខ្លួនមែន។ ឈ្មោះ [redacted] តារាវិន្ត ខ្ចីឡានខ្លួននៅម៉ោង៩យប់ ឯខ្លួននៅបន្ទប់ក្នុងសណ្ឋាគារដដែល។ តែការស្នាក់នៅរបស់ខ្លួនក្នុងសណ្ឋាគារពុំមានវិក័យបត្រទេ ។ ក្រោយពេលគេខ្ចីឡាន ខ្លួនបានទូរសព្ទ័រកឈ្មោះ [redacted] តារាវិន្តហ្វេត ហើយដល់ភ្លឺទើបវាយកឡានមកផ្ញើទុកនៅកន្លែងចតឡានឲ្យខ្លួន ដោយមិនបានជួបនិយាយគ្នាទេ ។ ឡានគេយកមកឲ្យនៅម៉ោង៥ទៅម៉ោង៦ព្រឹក ខ្លួនដឹងតាមអ្នកយាមប្រាប់ថា គេយកឡានមកឲ្យ គឺខ្លួននៅបន្ទប់លេខ៨ ហើយខ្លួនបានពិនិត្យឡានមិនឃើញមានស្នាមអ្វីទេ។នៅថ្ងៃកើតហេតុខ្លួនទូរសព្ទ័ទៅ ឈ្មោះ [redacted] តារាវិន្ត ដោយសារវាខ្ចីឡាន ហើយខ្លួនទទួលស្គាល់ថា ឡានជារបស់ខ្លួន តែខ្លួនមិនបានប្រព្រឹត្តអំពើនេះទេ ។សំណូមពរសុំបន្ធូរបន្ថយទោស។

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ ជនជាប់ចោទបដិសេធរាល់សកម្មភាពរបស់ខ្លួនដោយអះអាងថា ខ្លួនស្នាក់នៅសណ្ឋាគារហ្វេត តែគ្មានភស្តុតាងបញ្ជាក់ពីការស្នាក់នៅទេ ឃើញថា ការបដិសេធនេះមិនអាចជឿបានទេ។ ជនជាប់ចោទទទួលស្គាល់ថាឡានជារបស់ខ្លួន តែត្រូវបានឈ្មោះ [redacted] តារាវិន្តខ្ចី ប៉ុន្តែឈ្មោះ [redacted] តារាវិន្តក៏បានបដិសេធការចោទប្រកាន់ដែរ ឃើញថា ការចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រឹមត្រូវហើយ សុំក្រុមប្រឹក្សាពិនិត្យសម្រេចតាមច្បាប់។

មេធាវីផ្តល់សេចក្តីសន្និដ្ឋាន ៈឆ្លងតាមការពិនិត្យសំណុំរឿង ជនជាប់ចោទនៅតែអះអាងថាមិនបានប្រព្រឹត្ត បើផ្អែកលើតារាងទូរសព្ទ័បានបង្ហាញថា ទូរសព្ទ័ចេញនៅម៉ោង០០,១៣នាទីរហូតដល់ម៉ោង១,៥៤នាទី ដើម្បីទារឡាន នេះបញ្ជាក់ថា ជនជាប់ចោទមិននៅកន្លែងកើតហេតុនៅម៉ោង៥,១៥នាទីនិង៤៧វិនាទីទេ សុំក្រុមប្រឹក្សាពិចារណាសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ភារុណ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១១០កប៥ ចុះថ្ងៃទី០៧-១១-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

១៨០



Scanned with CamScanner

២-ជនជាប់ចោទបានឆ្លើយបដិសេធការចោទប្រកាន់ ដោយគ្រាន់តែទទួលស្គាល់ថា ឡាបង្កហេតុជារបស់ខ្លួន ប៉ុន្តែត្រូវមិត្តភក្តិឈ្មោះ [redacted] តាភវន្ត ខ្ចីជិះតាំងពីម៉ោង៩យប់ដល់ភ្លឺទើបយកទៅប្រគល់ឲ្យវិញដោយទុកចោលនៅសណ្ឋាគារ។ប៉ុន្តែឈ្មោះ [redacted] តាភវន្ត ក៏បានបដិសេធថាខ្លួនមិនបានប្រព្រឹត្តដែរ ឃើញថា ជនជាប់ចោទទាំងពីរឆ្លើយគេចវេសពីការទទួលខុសត្រូវ ដែលក្រុមប្រឹក្សាយល់ថា អ្នកទាំងពីរជាសហចារី ។

៣-ជនជាប់ចោទប្តឹងសុំបន្ធូរបន្ថយទោស ព្រោះខ្លួនមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីមុន ហើយសុំទៅរួមរស់ក្នុងសង្គមជាតិវិញ គប្បីតុលាការពិចារណាលើការសុំនេះ ព្រោះទណ្ឌកម្មដែលបានកំណត់ដោយសាលក្រមមានរយៈពេល៧ឆ្នាំ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ១១០កប៥ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុទី៣ ខាងលើដែលត្រូវកែតម្រូវឡើងវិញ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ភារុណ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១០ កប៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុច២-ក ត្រង់" ផ្តន្ទាទោសឈ្មោះ [redacted] ភារុណ ដាក់ពន្ធនាគារ០៧ឆ្នាំ "ត្រូវកែប្រែជា " ផ្តន្ទាទោសឈ្មោះ [redacted] ភារុណ ដាក់ពន្ធនាគារ៤ឆ្នាំ ៦ខែ " (បួនឆ្នាំ ប្រាំមួយខែគត់) ។ ចំណុចដទៃទៀតនៅរក្សាទុកជាបានការដដែល

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]